ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និងឈ្មោះសំណុំរឿង៖ ០២/១២-តេ យុង

កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **សេង វួចហ៊ុន**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **ទូន ស៊ីផាន់**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន តេ យុង (ខេមបូឌា)**

អាសយដ្ឋាន ៖ ភូមិបុរីកម្មករ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០៩៩ ៣២៣ ២៣១ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

- **ចូលរួមសវនាការលើកទី១ ៖**
  - លោក ប្រាក់ បូរ៉ាណែត ប្រធានគ្រប់គ្រងផ្នែករដ្ឋបាល
- **ចូលរួមសវនាការលើកទី២ ៖**
  - លោក ប្រាក់ បូរ៉ាណែត ប្រធានគ្រប់គ្រងផ្នែករដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហព័ន្ធសហជីពកម្មករកម្ពុជា**

- **សហជីពកម្មករកម្ពុជា រោងចក្រ TAE YOUNG CAMBODIA CO., LTD**

អាសយដ្ឋាន ៖ (បុរីសឡា) ផ្ទះលេខ៣០សេ ផ្លូវលេខ៣៧១ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ

លេខទូរស័ព្ទ ៖ ០១២ ៨៣៧ ៧៦៨ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

- **ចូលរួមសវនាការលើកទី១ ៖**

| | |
|---|---|
| ១- លោក ឃិន សុខន | អគ្គលេខាធិការសហព័ន្ធសហជីពកម្មករកម្ពុជា |
| ២- លោក ហ៊ួរ ពៅ | មន្ត្រីសហព័ន្ធសហជីពកម្មករកម្ពុជា |
| ៣- លោក ឡី សុជាតិ | កម្មករ |
| ៤- លោក ចន រ៉ាវី | កម្មករ |
| ៥- លោក វណ្ណ បុន | កម្មករ |
| ៦- លោក ជឹម ប៉េងធឿន | កម្មករ |
| ៧- លោក សន ផល្លី | កម្មករ |
| ៨- លោក ប៉ក់ ឧត្តម | កម្មករ |

- **ចូលរួមសវនាការលើកទី២ ៖**

| | |
|---|---|
| ១- លោក ចាយ សុភា | អគ្គលេខាធិការរងសហព័ន្ធសហជីពកម្មករកម្ពុជា |
| ២- លោក ឡី សុជាតិ | កម្មករ |
| ៣- លោក ចន រ៉ាវី | កម្មករ |
| ៤- លោក វណ្ណ បុន | កម្មករ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ភាគីកម្មករទាមទារក្រុមហ៊ុនទទួលយកកម្មករទាំងបីនាក់ ឈ្មោះ ឡី សុជាតិ, ចន រ៉ាវី និង វណ្ណ ប៊ុណ្ណ ជាថ្នាក់ដឹកនាំសហជីពកម្មករកម្ពុជា ឱ្យចូលធ្វើការនៅកន្លែងដដែល និងរក្សាប្រាក់រំលឹកផ្សេងៗ ចាប់ពីថ្ងៃបញ្ចប់កិច្ចសន្យាការងារ រហូតដល់ថ្ងៃចូលធ្វើការវិញ។ ភាគីក្រុមហ៊ុនមិនឯកភាព គឺក្រុមហ៊ុនបានដាក់លិខិតព្យួរការងារកម្មករទាំងបីរូបខាងលើ ទៅមន្ទីរការងារខេត្តកណ្ដាលរួចហើយ ដែលកំពុងស្ថិតនៅក្នុងនីតិវិធីរបស់មន្ទីរការងារខេត្តនៅឡើយ ហើយក្រុមហ៊ុនពុំបានបញ្ចប់កិច្ចសន្យាការងារទេ រហូតមកដល់ពេលនេះ សូមរក្សាប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំជូនសាមីជនដដែល។

២- ភាគីកម្មករទាមទារឱ្យក្រុមហ៊ុនដកប្រធានផ្នែក ឈ្មោះ ខេង បូរី ភេទស្រី ផ្នែកដេរ ចេញពីការងារ ពីព្រោះគាត់នៅតែជេរប្រមាថ និងស្រែកខ្លាំងៗដាក់កម្មករដដែល (មិនអនុវត្តកិច្ចព្រមព្រៀង នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ ២០១១)។ ភាគីក្រុមហ៊ុនមិនឯកភាព គឺសុំអនុវត្តតាមនីតិវិធីរដ្ឋបាលត្រឹមត្រូវរបស់ក្រុមហ៊ុន។

៣- សុំឱ្យក្រុមហ៊ុនដកប្រធានផ្នែក សូត្រ រិទ្ធី និង គ្រុយ រតនា ចេញពីការងារ ពីព្រោះឈ្មោះនេះនៅតែជេរ

កម្មករដដែល។ ក្រុមហ៊ុនបានណែនាំអប់រំផ្ទាល់មាត់លើកទី១ និងណែនាំអប់រំជាលាយលក្ខណ៍អក្សរលើកទី២ តាមនីតិវិធីរួចហើយ ដល់សាមីជនទាំងបីរូបនេះ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលទទួលអំណាចក្នុងការចេញសេចក្ដីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្ដីពីការងារឆ្នាំ១៩៩៧ ប្រកាសស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្ដីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្ដីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្ដីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្ដីអំពីការមិនសះជាលេខ ០៣៤ កប/កណ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១២ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្ដាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

**កាលបរិច្ឆេទសវនាការ ៖**

- លើកទី១ ៖ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១២ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល)។
- លើកទី២ ៖ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក)។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ មន្ទីការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តកណ្ដាល បានដំណើរការផ្សះផ្សាវិវាទការងាររួមចំនួន០៨ចំណុច ដែលទទួលលទ្ធផលសះជានឹងគ្នាចំនួន៥ចំណុច និងមិនសះជាចំនួន៣ចំណុច។ ចំណុចមិនសះជា៣ចំណុចដែលនៅសល់ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១២ តាមរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួមមិនសះជា ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៣ ចំណុចនេះ ចំនួនពីរលើក នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២ វេលាម៉ោង ២ រសៀល និងម្ដងទៀត នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២ វេលាម៉ោង ០៨ និង៣០នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការ

THE ARBITRATION COUNCIL

ផ្សះផ្សាចំណុចមិនសះជាចំនួន ០៣ ចំណុចនេះបន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០២ ចំណុច គឺចំណុចវិវាទទី២ និងទី៣។ ចំណុចដែលនៅសល់ គឺចំណុចវិវាទទី១។

ដោយសារភាគីទាំងពីរជាហត្ថលេខីនៃអនុស្សារណៈនៃការយោគយល់គ្នាចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដូចនេះ ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបែងចែកសេចក្តីសម្រេចនៃចំណុចវិវាទជាពីរ គឺចំណុចវិវាទអំពីសិទ្ធិ និងចំណុចវិវាទអំពីប្រយោជន៍។ ភាគីទាំងពីរមិនមានសិទ្ធិប្តឹងជំទាស់លើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើ ចំណុចវិវាទអំពីសិទ្ធិនោះទេ ព្រោះភាគីទាំងពីរបានព្រមព្រៀងគ្នា ឱ្យសេចក្តីសម្រេចនេះជាសេចក្តីសម្រេច ដែលជាប់កាតព្វកិច្ចតាមរយៈអនុស្សរណៈនៃការយោគយល់គ្នាចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ រួចហើយ។ ប៉ុន្តែ ភាគីអាចប្តឹងជំទាស់ទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើវិវាទអំពីប្រយោជន៍ ប្រសិនបើភាគីជ្រើសរើសយកសេចក្តីសម្រេចមិនជាប់កាតព្វកិច្ចចំពោះវិវាទអំពីប្រយោជន៍។ ការប្តឹងជំទាស់របស់ភាគីទៅនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើចំណុចវិវាទអំពីប្រយោជន៍ នឹងមិនបណ្តាលឱ្យប៉ះពាល់ទៅដល់កាតព្វកិច្ចក្នុងការអនុវត្តសេចក្តីសម្រេច ដែលជាវិវាទអំពីសិទ្ធិទេ ដោយអនុលោមតាមស្មារតីនៃអនុស្សារណៈនៃការយោគយល់គ្នាខាងលើនោះ។

ក្នុងសំណុំរឿងនេះ ភាគីទាំងពីរជ្រើសរើសយកសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីផលប្រយោជន៍។ សេចក្តីបង្គាប់នៃសំណុំរឿងនេះ ត្រូវចេញនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ ប៉ុន្តែ ភាគីទាំងពីរឯកភាពពន្យារពេលរហូតដល់ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន តេ យុង (ខេមបូឌា) ខូអិលធីឌី គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំផ្ទេរសិទ្ធិជូនលោក ប្រាក់ បូរ៉ាំណែត ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១។

២- លិខិតជូនដំណឹងធ្វើកូដកម្ម របស់ថ្នាក់ដឹកនាំសហជីព និងកម្មករ-កម្មការិនី រោងចក្រ តេ យុង ខេមបូឌា ខូអិលធីឌី សូមជម្រាបមក លោកនាយកក្រុមហ៊ុន តេ យុង ខេមបូឌា ខូអិលធីឌី ស្តីពីការជូនដំណឹង ០៧ ថ្ងៃ ធ្វើកូដកម្ម ឬបាតុកម្មអហឹង្សា ដើម្បីជំរុញឱ្យក្រុមហ៊ុនអនុវត្តនូវកិច្ចព្រមព្រៀង ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១១ និងលក្ខណ្ឌការងារមួយចំនួន ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១១។

៣- ដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកណ្តាល សំណុំរឿងរក្សាការពារ លេខ ៥២ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១១។

៤- លក្ខន្តិកៈរបស់ក្រុមហ៊ុន តេ យ៉ុង (ខេមបូឌា) ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១១។

៥- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន តេ យ៉ុង (ខេមបូឌា) លេខ ២៥៧៤ ពណ.ចបព ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១។

៦- លិខិតលេខ HR-Admin-017-12/2011TYC ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១១ របស់នាយកក្រុមហ៊ុន តេ យ៉ុង (ខេមបូឌា) ខូអិលធីឌី ជម្រាបមក លោក ឡី សុជាតិ ស្តីពីការព្យួរការងារលោកមួយរយៈ ចាប់ពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១១ នេះតទៅ។

៧- កំណត់ហេតុស្តីពីការផ្តល់ព័ត៌មានរបស់លោក ឡី សុជាតិ, លោក ចន វ៉ារី និង លោក វណ្ណ បុន ដែលត្រូវក្រុមហ៊ុន តេ យ៉ុង ព្យួរការងារ ចាប់ពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១១។

៨- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុនកាត់ដេរ តេ យ៉ុង ចុះបញ្ជិកាលេខ ៣៧៩/១១ ក.ប.វ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១១។

៩- ស្នាមមេដៃរបស់កម្មករ-កម្មការិនី នៃរោងចក្រ តេ យ៉ុង គាំទ្រ និងចូលរួមធ្វើកូដកម្មថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១។

១០- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងារបុគ្គល របស់ក្រុមហ៊ុន តេ យ៉ុង ជាមួយ ឈ្មោះ ចន វ៉ារី ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២។

១១- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងារបុគ្គល របស់ក្រុមហ៊ុន តេ យ៉ុង ជាមួយ ឈ្មោះ ឡី សុជាតិ ចុះថ្ងៃ ទី១៧ ខែមករា ឆ្នាំ២០១២។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- វិញ្ញាបនប័ត្រចុះបញ្ជិការបស់សហជីពកម្មករកម្ពុជា រោងចក្រ TAE YOUNG CAMBODIA CO., LTD ចុះបញ្ជិកាលេខ ២២៥៩ ក.ប/វក. ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១។

២- លិខិតលេខ ២៣៣ ក.ប ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមបញ្ជាក់ថា សហជីពកម្មករកម្ពុជា រោងចក្រ TAE YOUNG CAMBODIA CO., LTD ជាអង្គការវិជ្ជាជីវៈមួយរបស់កម្មករនិយោជិត ត្រូវបានចុះបញ្ជិកានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈពេញលក្ខណៈច្បាប់ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជិកានេះតទៅ។

៣- ស្នាមមេដៃរបស់កម្មករ-កម្មការិនី នៃរោងចក្រ តេ យ៉ុង គាំទ្រ និងចូលរួមធ្វើកូដកម្មថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន តេ យ៉ុង លេខ ០៣៤/១១ គប/កណ.ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន តេ យ៉ុង ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១១ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៣២ កប/អក/វក/លកអ. ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៣៣ កប/អក/វក/លកអ. ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ ។

៣- ការព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីសិទ្ធិ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១២ ។

៤- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី២ លេខ ០៥៦ កប/អក/វក/លកអ. ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ ។

៥- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៥៧ កប/អក/វក/លកអ. ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១២ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន តេ យុង ចាប់ដំណើរការ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១។ បច្ចុប្បន្ន ក្រុមហ៊ុនមានជួលកម្មករនិយោជិត សរុបចំនួន ៦៤៧ នាក់។
- នៅក្នុងក្រុមហ៊ុនមានសហជីពចំនួនបី គឺសហជីពកម្មករកម្ពុជា សហជីពខ្មែរ និងសហជីពសម្លេងយុវជនខ្មែរ។ សហជីពកម្មករកម្ពុជា ជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ និងមានសមាជិកចំនួន ៤៧២ នាក់។

**ចំណុចវិវាទទី១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកថ្នាក់ដឹកនាំសហជីព ឈ្មោះ ឡី សុជាតិ, ចន រ៉ាវី និង វណ្ណ បុន និងសងប្រាក់រំលឹកផ្សេងៗ ចាប់ពីថ្ងៃបញ្ឈប់ពីការងារ រហូតដល់ថ្ងៃចូលធ្វើការវិញ**

- កម្មករ ឡី សុជាតិ បានចូលធ្វើការនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១១ ផ្នែកដេរ មានកិច្ចសន្យាការងារដែលមានថិរវេលាមិនកំណត់ និងមានតួនាទីជាប្រធានសហជីពកម្មករកម្ពុជា។
- កម្មករ ចន រ៉ាវី បានចូលធ្វើការនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ផ្នែកដេរ មានកិច្ចសន្យាការងារ ដែលមានថិរវេលាមិនកំណត់ និងមានតួនាទីជាអនុប្រធានសហជីពកម្មករកម្ពុជា។
- កម្មករ វណ្ណ បុន បានចូលធ្វើការនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ ផ្នែកដេរ មានកិច្ចសន្យាការងារ ដែលមានថិរវេលាមិនកំណត់ និងមានតួនាទីជាលេខាធិការសហជីពកម្មករកម្ពុជា។

- នៅក្នុងក្រុមហ៊ុន មានគោលការណ៍ផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តដល់កម្មករនិយោជិត ដែលដេរគ្រប់តាមបរិមាណផលិតផល មួយថ្ងៃ មួយពាន់រៀល រៀងរាល់ថ្ងៃដែលកម្មករនិយោជិតដេរបាន។ ក្រោយមកនិយោជកធ្វើការផ្លាស់ប្តូររបៀបនៃការផ្តល់នេះ ដោយធ្វើការផ្តល់ជូនកម្មករនិយោជិតមួយថ្ងៃ មួយពាន់រៀល តែក្នុងករណីដែលគាត់ដេរគ្រប់បរិមាណផលិតផល ជាប់គ្នាមួយសប្តាហ៍ពេញ ប៉ុន្តែ កម្មករនិយោជិតមិនយល់ស្រប ។ ថ្នាក់ដឹកនាំសហជីពទាំងបីនាក់ធ្លាប់បានចរចាជាមួយនិយោជកម្តង ពីបញ្ហានេះ កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០១១ ប៉ុន្តែនិយោជកមិនយល់ព្រម ។
- នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ថ្នាក់ដឹកនាំសហជីពទាំងបីបានចរចាជាមួយនិយោជកម្តងទៀត ប៉ុន្តែនិយោជកនៅតែមិនយល់ព្រម ។ ពេលនោះ ថ្នាក់ដឹកនាំសហជីពទាំងបីបានពាំនាំលទ្ធផលនៃការចរចាប្រាប់ទៅកម្មករនិយោជិត ។ នៅថ្ងៃដដែល ក៏មានការផ្ទុះកូដកម្មនៅក្នុងក្រុមហ៊ុន ។
- ភាគីនិយោជកបានចោទប្រកាន់ថា ថ្នាក់ដឹកនាំសហជីពទាំងបីញុះញង់កម្មករនិយោជិតឱ្យធ្វើកូដកម្ម ដែលជាកំហុសធ្ងន់ ផ្អែកតាមមាត្រា ៨៣ (ខ) ត្រង់ចំណុចទី៥ នៃច្បាប់ស្តីពីការងារ ។ ជាលទ្ធផល និយោជកព្យួរការងារអ្នកទាំងបី នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ នោះតែម្តង និងបានសម្រេចបញ្ឈប់ពីការងារ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១២ ដោយបានជូនដំណឹងដល់ពួកគាត់ជាមុន កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២។ និយោជកបានបើកប្រាក់ឈ្នួលចុងក្រោយ នៃថ្ងៃធ្វើការក្នុងខែធ្នូ ឆ្នាំ២០១១ ឱ្យកម្មករនិយោជិតរួចរាល់ហើយ ។
- ភាគីនិយោជកបានស្នើសុំបញ្ឈប់ថ្នាក់ដឹកនាំសហជីពទាំងបីទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ ។
- មកត្រឹមកាលបរិច្ឆេទដាក់ភស្តុតាង ដោយភាគីទាំងពីរ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានទទួលភស្តុតាងណាមួយពីភាគីនិយោជកទាក់ទងនឹងការឆ្លើយតបរបស់អធិការការងារលើការស្នើសុំបញ្ឈប់ថ្នាក់ដឹកនាំសហជីពទាំងបីនោះទេ ។ ចំណែកឯ ភស្តុតាងដែលនិយោជកបានដាក់មកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ ដែលបានហួសកាលកំណត់កាលបរិច្ឆេទនោះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនពិចារណាទេ ។

## **ហេតុផលនៃសេចក្តីសម្រេច**

**ចំណុចវិវាទទី១ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកថ្នាក់ដឹកនាំសហជីពឈ្មោះ ឡី សុជាតិ, ចន រ៉ាវី និង វណ្ណ បុន និងសងប្រាក់រំលឹកផ្សេងៗ ចាប់ពីថ្ងៃបញ្ឈប់ពីការងារ រហូតដល់ថ្ងៃចូលធ្វើការវិញ**

មុននឹងពិចារណាចំណុចវិវាទនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការទាមទារក្នុងចំណុចនេះជាវិវាទអំពីសិទ្ធិដែរ ឬទេ?

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា “*វិវាទអំពីសិទ្ធិ គឺជាវិវាទទាក់ទងនឹងសិទ្ធិដែលមានចែងក្នុងច្បាប់ កិច្ចព្រមព្រៀង ឬអនុសញ្ញារួមណាមួយចែងពីការទាមទារនោះ*” ។ (សូមមើលសេចក្តីសម្រេច

*អាជ្ញាកណ្តាលលេខ ០៥/១១-អ៊ីម វ៉េ (សាខាទី១) ហេតុផលចំណុចវិវាទទី១ និង៥, លេខ ១៣/១១-ហ្គូល កាំវីម៉ិច ហេតុផលចំណុចវិវាទទី១ និង២ និងលេខ ១៤/១១-ជី អេច ជី ហេតុផលចំណុចវិវាទទី៤) ។*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿង ខាងលើដែរ គឺចំណុចវិវាទដែលទាក់ទងនឹងការសុំចូលធ្វើការវិញ និងការសងរំលឹកប្រាក់ឈ្នួល ជាវិវាទដែលមានចែងក្នុងច្បាប់ស្តីពីការងារ គឺជាវិវាទអំពីសិទ្ធិ ។

មាត្រា ២៩៣ នៃច្បាប់ស្តីពីការងារបានចែងថា *"រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាមួយពីការងាររបស់ខ្លួន អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីអធិការការងារ ។...*

*អធិការការងារ ដែលបានទទួលពាក្យបណ្តឹងសុំបញ្ឈប់កម្មករនិយោជិត ដូចមានចែងក្នុងមាត្រានេះ ត្រូវផ្តល់សេចក្តីសម្រេចរបស់ខ្លួនដល់និយោជក ដល់កម្មករនិយោជិតដែលត្រូវបញ្ឈប់... ក្នុងរយៈពេលមួយខែយ៉ាងយូរក្រោយពីទទួលពាក្យបណ្តឹង ។*

*បន្ទាប់ពីទទួលបានសេចក្តីសម្រេចនោះ និយោជកកម្មករនិយោជិត ដែលត្រូវបញ្ឈប់ ឬអង្គការសហជីពរបស់កម្មករនិយោជិតនោះ មានរយៈពេលពីរខែ ដើម្បីធ្វើឧបាស្រ័យ ទៅរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ ។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ អាចបដិសេធចោល ឬកែសម្រួលសេចក្តីសម្រេចរបស់អធិការការងារ ។*

*បើគ្មានការជូនដំណឹងអំពីសេចក្តីសម្រេចរបស់អធិការការងារ ក្នុងរយៈពេលដែលបានកំណត់ឱ្យទេ ឬបើគ្មានការជូនដំណឹងអំពីសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារក្នុងរយៈពេលពីរខែ បន្ទាប់ពីទទួលបណ្តឹងឧបាស្រ័យតាមឋានានុក្រមនោះ ពាក្យបណ្តឹង និងឧបាស្រ័យនោះ ត្រូវចាត់ទុកថាបានបដិសេធចោល "* ។

មាត្រានេះ ក៏ត្រូវបានអនុវត្តចំពោះថ្នាក់ដឹកនាំសហជីពផងដែរ ដូចមានចែងក្នុងប្រការ ៤ នៃប្រកាសលេខ ៣០៥ សកបយ. ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដែលចែងថា *" ... ការការពារនេះ ត្រូវបានផ្តល់ឱ្យថ្នាក់ដឹកនាំសហជីព ០៣ រូបក្នុងលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ២៨២ និង ២៩៣ នៃច្បាប់ស្តីពីការងារ "* ។

យោងតាមមាត្រា ២៩៣ នៃច្បាប់ស្តីពីការងារ គឺតម្រូវឱ្យនិយោជកធ្វើលិខិតស្នើសុំបញ្ឈប់កម្មករនិយោជិតដែលជាថ្នាក់ដឹកនាំសហជីពទៅអធិការការងារ ។

ផ្អែកតាមអង្គហេតុ ភាគីនិយោជកបានស្នើសុំបញ្ឈប់ថ្នាក់ដឹកនាំសហជីពទាំងបីទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ ។ គិតមកត្រឹមកាលបរិច្ឆេទដាក់ភស្តុតាង ដោយភាគីទាំងពីរ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២ គឺមានរយៈពេលលើសពីមួយខែហើយ ប៉ុន្តែ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានទទួលភស្តុតាងពីភាគីនិយោជក ទាក់ទងទៅនឹងការឆ្លើយតបរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទៅលើការស្នើសុំបញ្ឈប់ថ្នាក់ដឹកនាំសហជីពទាំងបីនាក់នេះទេ ។

យោងមាត្រា ២៩៣ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការមិនឆ្លើយតបរបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទៅលើការស្នើសុំបញ្ឈប់ថ្នាក់ដឹកនាំសហជីពទាំងបីនាក់ មានន័យថា ការស្នើសុំនោះ ត្រូវ

ចាត់ទុកថា បានបដិសេធចោល។ ក្រៅពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏មិនបានទទួលភស្តុតាងដទៃទៀត ទាក់ទង នឹងការប្តឹងឧបាស្រ័យដែរ។

លើសពីនេះ មាត្រា ២៩៥ ចែងថា *"ករណីមានកំហុសធ្ងន់ នាយកសហគ្រាសអាចចេញសេចក្តីសម្រេច បញ្ឈរជើងសាមីខ្លួនភ្លាមៗបាន ក្នុងការរង់ចាំសេចក្តីសម្រេចរបស់អធិការការងារ។ ក្នុងករណីដែលអធិការងារ មិនយល់ព្រមឱ្យបញ្ឈប់ការងាររបស់សាមីខ្លួនទេ ការបញ្ឈរជើងនេះ ត្រូវទុកជាមោឃៈ ហើយផលនៃការបញ្ឈរជើង នេះ ក៏ត្រូវលុបចោលដោយពេញច្បាប់ដែរ"*។

នៅក្នុងសំណុំរឿងនេះ និយោជកបានចោទប្រកាន់ថា ថ្នាក់ដឹកនាំសហជីពទាំងបីនាក់បានប្រព្រឹត្តកំហុសធ្ងន់។ ហេតុនេះ និយោជកបានសម្រេចព្យួរកិច្ចសន្យាការងារថ្នាក់ដឹកនាំសហជីពទាំងបីនាក់ភ្លាម។ ប៉ុន្តែ មកដល់ថ្ងៃផុត កំណត់ដាក់ភស្តុតាងនេះ ត្រូវចាត់ទុកថា បានបដិសេធចោលរួចហើយលើការស្នើសុំបញ្ឈប់នេះ។ ហេតុនេះ យោង តាមមាត្រា ២៩៥ នៃច្បាប់ស្តីពីការនេះ ផលនៃការបញ្ឈរជើង មានន័យថា ការមិនត្រូវបានអនុញ្ញាតឱ្យធ្វើការ និង ការមិនទទួលប្រាក់ឈ្នួលពីនិយោជក ត្រូវលុបចោល ដោយពេញច្បាប់។

ជាមួយគ្នានេះ ប្រការ៣៤ នៃប្រកាស ០៩៩ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា *"...ក្រុមប្រឹក្សាអាជ្ញា កណ្តាលមានសិទ្ធិ និងអំណាចក្នុងការសម្រេចឱ្យភាគីវិវាទផ្តល់នូវសំណងវដ្តប្បវេណី ឬសំណងខូចខាត ដែលមាន លក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ ដោយរួមទាំងការ ក.បញ្ជាឱ្យទទួលយកកម្មករនិយោជិត ដែលបានបណ្តេញចេញ ឱ្យចូលមកធ្វើការវិញ...ខ. បញ្ជាឱ្យបង់ប្រាក់ជាបន្ទាន់នូវប្រាក់ដែលត្រូវបង់..."*។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បង្គាប់ឱ្យនិយោជកទទួលយកលោក ឡី សុជាតិ, លោក ចន រ៉ាវី និង លោក វណ្ណ បុន ឱ្យចូលធ្វើការវិញ និងសងប្រាក់រំលឹកពីថ្ងៃព្យួរកិច្ចសន្យាការងារ រហូតដល់ថ្ងៃទទួលចូលធ្វើការវិញ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**១- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ:**

**ចំណុចវិវាទទី១ ៖**

បង្គាប់ឱ្យនិយោជកទទួលយកលោក ឡី សុជាតិ លោក ចន រ៉ាវី និង លោក វណ្ណ បុន ឱ្យចូលធ្វើការវិញ និង សងប្រាក់រំលឹក ចាប់ពីថ្ងៃព្យួរកិច្ចសន្យាការងារ រហូតដល់ថ្ងៃទទួលចូលធ្វើការវិញ។

**ប្រភេទនៃសេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ:**

សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសេចក្តីសម្រេចផ្នែកទី១នេះ នឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង ដោយយោងតាមអនុស្សារណៈនៃការយោគយល់គ្នា ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១០។

THE ARBITRATION COUNCIL

**២- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ ÷ គ្មាន**

ប្រភេទនៃសេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍ ៖

សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីសម្រេចផ្នែកទី២នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **សេង ឡុចហ៊ុន**

ហត្ថលេខា: ------------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **ឡុង ស៊ីផាន់**

ហត្ថលេខា: ------------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល ៖**

ឈ្មោះ ៖ **ប៉ែន ម៉ុនឈា**

ហត្ថលេខា: ------------------------------------